## ដកស្រង់ ឱវាទ

# ព្រះគ្រូសមថវីរិយោ ប៉ក់ សុយ

ព្រះចៅអធិការ វត្តកច្ចបប់ពតី

( ភ្នំអណ្តើក )

៩២.
៨៦១

www.budinst.gov.kh www.elibraryofcambodia.org

## **ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

២៩២.ឃ៦ខ



ព្រះគ្រូ សមថវីរិយោ ប៉ក់ . សយ

ព្រះចៅ អធិការវត្ត កច្ឆបបពាតិ

( ភ្នំអណ្តើក )

ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
០៩៩៩/០៣

www.budinst.gov.kh www.elibraryofcambodia.org

꧁

# ឧទ្ទិសកថា

*******

ក្រាបប្រគេនមហាកុសលចេតនាចំពោះព្រះគ្រូសមថវីរយោ ប៉ក់ សយ ក្នុងនិកាសបុណ្យឈាបនកិច្ចព្រះគ្រូ ។

សៀវភៅដែលខ្ញុំព្រះករុណាខ្ញុំបាទ រៀបរៀងចងក្រងសរសេរនេះ គ្រាន់តែមួយចំណែកនៃនិវាទរបស់ព្រះគ្រូសមថវីរយោ ប៉ក់ .សយ កាលដែលព្រះគ្រូទ្រង់និវាទចំពោះសិស្សគណមានដូនជី តាជី ជាដើមចូលជ្រៅខាងសមថកម្មដ្ឋាន ចំរើនភាវនា មានការចំរើននៅត្រ័យលក្ខណ៍៤០ជាដើម។

ម្យ៉ាងទៀតនោះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា នូវកុសលចេតនាក្នុងការបរិច្ចាកប្រាក់ដោយកំលាំងសទ្ធាពិតៗ របស់ញាតិញោម ពុទ្ធបរិស័ទ វត្តខ្មែរសន្សំកុសល នៅកាលីហ្វ័រនីញ៉ា ( ស.រ.អា ) មានព្រះគ្រូទក្ខប្បញ្ញោ អៀ . សៅ ជាព្រះប្រធានក្នុងការកសាងស្ថានព្រះហស្តរបស់ព្រះគ្រូ សមថវីរយោ ប៉ក់ . សយ ទុកជាទីគោរពសក្ការៈ បដិបត្តិ សមថកម្មដ្ឋាន ។

សូមពុទ្ធបរិស័ទបានសំរេចនូវ បញ្ញា ដ៏ឧត្តម បានដល់នូវការរំលត់សេចក្តីប្រកាន់បញ្ចក្ខន្ធ ធ្វើដំណើរចេញចាកខន្ធទៅកាន់ព្រះនិព្វានកុំបីខានឡើយ ។

ខ្ញុំព្រះករុណាខ្ញុំបាទដែលជាសិស្សគណព្រះគ្រូ

ធម្មាចារ្យ ស្វាន . អន

www.budinst.gov.kh www.elibraryofcambodia.org

# សំនេរជីវប្រវត្តិ

## ព្រះគ្រូកម្មដ្ឋានាចារ្យ សមថវីរិយោ ម៉ក់ . សយ
## ព្រះចៅអធិការវត្តកន្ទួបបទតី ( ភ្នំរណ្តើក )

*****************

ព្រះគ្រូកម្មដ្ឋានាចារ្យ ព្រះនាមសមថវីរិយោ ម៉ក់ . សយ ទ្រង់ប្រសូត្រនៅនាតិថី ថ្ងៃព្រហស្បតិ៍ មាសា ភទ្របទទី នៃសំវច្ឆរ ឆ្នាំវក សិរិទ្ធស័ក ក្នុង ព.ស ២៤៦៣ ត្រូវនឹង គ.ស ១៩១៧ នៅក្នុងមណ្ឌលភូមិពោធិ៍ ឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បិតាមាននាម ពៅ ម៉ក់ មាតាមាននាម មី . ញ៉ុង មានបងប្អូនបង្កើត៥រូប ព្រះអង្គជាបុត្រទី៤ ត្រូវមាតាទទួលមរណកាលចោលតាំងតែពីបឋមវ័យ ៤ខួបមកម្លេះ ពេលដែលកុមារ មានអាយុ១៤ឆ្នាំ បិតាបានបញ្ជូនអោយទៅសិក្សា អក្សរសាស្ត្រ បេខនពុទ្ធ ក្នុងសំណាក់ព្រះចៅអធិការវត្តស្រះឃ្លាំងព្រះនាមអ៊ុន។

ក្នុងឱកាសសិក្សានោះមានសមត្ថភាពរៀនពូកែ ហើយប៉ិនប្រសព្វធ្វើកិច្ចវត្ត ដល់គ្រូអាចារ្យលើសបណ្តាសិស្សកុមារវត្តនានា លុះដល់អាយុបាន ១៦ឆ្នាំ កុលបុត្ររូបនេះបានសុំលាបិតា ដើម្បីបព្វជ្ជាក្នុងព្រះពុទ្ធសាសនា កាលបើបានសំរេចភេទជាបព្វជិត ដូច្នេះហើយ សាមណេររូបនេះ ជាបុគ្គលដែលបរិបូរណ៍ដោយសមណសារុប្ប និងដល់ព្រះទៅដោយអភិសមាចារវត្ត

www.budinst.gov.kh www.elibraryofcambodia.org

ចំពោះឧបជ្ឈាយ៍ និងអាចារ្យ ។

ពីវស្សាកន្លងផុតស្រមោលទៅ តាមថ្ងៃខែសារបណ្ឌិតក៏លាចាកសិក្ខាបទមកកាន់ភេទជាឧបាសកវិញ ត្បិតឃើញបញ្ហាជីវភាពញោមបិតាលំបាកពេក ទោះបីជាស្ថិតនៅក្នុងភាពជាឃរាវាសវិស័យវិញក៏ដោយ បណ្ឌិតនៅតែប្រកាន់ខ្ជាប់នូវសីលធម៌ សុជីវធម៌ជារៀងដរាប ។ ការទទួលបន្ទុកក្នុងគ្រួសារនេះគឺ បណ្ឌិតប្រកបអាជីវកម្មឡើងត្នោត និងកសិកម្មធ្វើស្រែតែម្នាក់ឯង មិនត្រឹមតែប៉ុណ្ណោះបាននាំយកទិន្នផល ឧបត្ថម្ភដល់ព្រះពុទ្ធសាសនាដ៏ច្រើនលើសលុបហួសពីការគណនា សម័យថ្ងៃក្រោយមកទៀតបានវេលាល្អហើយ បិតារបស់បណ្ឌិតបានផ្សំផ្គុំរៀបអាពាហ៍ពិពាហ៍ជាមួយនិងបុត្រីរបស់លោក គល់ ប៉ុយ និង អ្នកស្រី ស ម៉ែន ដែលរស់នៅរួមមាតុភូមិជាមួយគ្នា ភារកិច្ចប្រពៃណីសំរេចហើយ គូស្វាមីភរិយានៅតែចាប់មុខរបរអាជីវកម្មឡើងត្នោត និងកសិកម្ម ធ្វើស្រែតាមសុច្ចរិតធម៌ដដែល ។ ទាន់សសហេស ( ខែ១២ ) កន្លងទៅភរិយាបណ្ឌិតក៏បានប្រសូត្របានបុត្រីមួយរូបតែអនិច្ចាបុត្រីរបស់បណ្ឌិតមានអាយុបានត្រឹមតែ៨ខួបប៉ុណ្ណោះ ត្រូវស្លាប់ដោយការរាតត្បាតជំងឺអុត ក្នុងកាលជាបន្តបន្ទាប់មក បិតាត្រូវថែកឋានចោលទៀតព្រោះអាស្រ័យកត្តាការវិនាសញាតិប្រាកដមានឡើងដូច្នេះ ស្រាប់តែបណ្ឌិតមានការឈ្វេងយល់ថា “វត្ថុទាំងឡាយណាឱ្យតែប្រាកដមានវត្ថុនោះនឹងដល់សភាពសាបសូន្យទៅវិញជាធម្មតា ” ហើយក៏លះបង់ការគ្រប់គ្រងផ្ទះសំបែងទៅសិក្សាព្រះកម្មដ្ឋានបាន៣ឆ្នាំ សុំលាឧបាសិកាភរិយាដើម្បីសាងព្រះផ្នួស

www.budinst.gov.kh www.elibraryofcambodia.org

ឧបសម្បទាជាភិក្ខុភាវហើយ ប៉ុន្តែការផ្នួសនេះមិនបានយូរប៉ុន្មានឡើយត្រូវវិលមកកាន់ភេទជាឧបាសកវិញ ដោយសង្គមសម័យនោះភ្លើងសង្គ្រាមជះឥទ្ធិពលនិងមានការជ្រួលច្របល់ខ្លាំងពេក ។

សូម្បីមានភេទជាឧបាសកដូច្នេះក៏ដោយ បណ្ឌិតរូបនេះនៅតែផ្តួងវិរិយភាពសិក្សាព្រះកម្មដ្ឋានបន្ថែមទៀតផង និង ជួយផ្តល់ឧបទេស (ណែនាំ) ដល់ពុទ្ធបរិស័ទ ដែលមានអធ្យាស្រ័យចូលចិត្តព្រះកម្មដ្ឋានផងដែរ ក្នុងចលនានៃការសិក្សាវិជ្ជាព្រះកម្មដ្ឋានទោះបីជាស្ថិតនៅក្នុងកាលទេសៈប្រភេទសង្គមអ័ព្ទអួរដោយឥទ្ធិពលភ្លើងសង្គ្រាមមែនពិត ប៉ុន្តែបណ្ឌិតនៅតែព្យាយាមក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ និង សង្វាតផ្ទៀងផ្ទាត់វិជ្ជានេះឯងរហូតអស់គណៈគ្រូធម្មាចារ្យ ១៤រូប សុទ្ធតែបានទទួលការសរសើរដោយន័យផ្សេងៗ ជាពិសេសក្នុងចំណោមគ្រូធម្មាចារ្យទាំងនោះ មានព្រះគ្រូអាចារ្យសមាធិរតោស្រី នុត បានព្យាករណ៍ចំពោះគុណសម្បត្តិរបស់បណ្ឌិតថាលែងវង្វេងហើយរហូតមកដល់ព្រះសាសនា កន្លងបាន២៥១៣វស្សា ឧបាសកជាធម្មាចារ្យបានសំរេចញត្តិចតុត្ថកម្មវាចា ជាភិក្ខុភាវម្តងទៀត ព្រមទាំងបានធ្វើដំណើរនិមន្តកាត់តាមបណ្តាខេត្តនានា រហូតបាននិមន្តមកដល់ខេត្តបាត់ដំបងយើងនេះក្នុងឆ្នាំ១៩៧៣ ហើយគង់ស្នាក់នៅតាមតំបន់នានាក្នុងខេត្ត ដូចជា ÷ ភ្នំតាលុន ( ភ្នំទ្រុងមាន់ ) ភ្នំក្តោង ភ្នំក្រពើ ភ្នំគីរីជុំ ភ្នំននោង ភ្នំក្រវាញ ភ្នំបាត...ជាដើម ។

ក្នុងឆ្នាំ១៩៧៥ ព្រះគ្រូធម្មាចារ្យបានមកគង់នៅក្នុងអារាមកច្ឆបបពត៌

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

( ភ្នំអំណើក ) នេះបានតែមួយឆ្នាំប៉ុណ្ណោះ ។

ក្រោយមកទៀតនៅឆ្នាំ១៩៧៩ ក៏បានបព្វជ្ជា ជាសាមណេរគាវ ២ឆ្នាំ ក្រោយមកទៀតទើបឧបសម្បទាជាភិក្ខុ ការបព្វជ្ជា និងឧបសម្បទាជាភិក្ខុនេះ បានមកគង់នៅវត្តកច្ចបបពតិ ទាំងដែលពេលនោះនៅវត្តនេះគ្មានឧបករណ៍ វត្ថុប្រើប្រាស់តាមសេចក្តីត្រូវការដូចសម័យបច្ចុប្បន្ននេះទេ ពុទ្ធបរិស័ទ ដែលធ្លាប់ឮការនិទានអំពីសម្បត្តិរបស់វត្តនេះមុនដំបូងថា មានត្រឹមតែកុដិដែលសាងសង់ដោយដីដ៏ចាស់មួយខ្នង មានឆ្នាំង២ ចាន៥ ផ្តិលទឹក១ និងសៀវភៅប្រជុំភាណវាររហែកកណ្តាល១ក្បាល ដែលបានមកពីការដូរអង្ករប៉ុណ្ណោះ ឥឡូវនេះសមិទ្ធិផលធំៗ ដែលហួសពីការស្មានដល់កើតឡើង ក្នុងអារាមភ្នំអណើក និង អច្ឆរិយវត្ថុអស្ចារ្យទាំង៥ ក៏ត្រូវបាននិមន្តអំពីអរិយប្រទេសមកកាន់ទីនេះផងដែរ ។

សម្បត្តិគរុភណ្ឌទាំងពួងបើយើង គណនាជាតំលៃទឹកប្រាក់ចំនួន ៦៦១.៦៤៣.៩០០រៀល នេះដោយយើងមិនបានគណនាតំលៃសាលាធម្មសភាដែលមានបណ្តោយ២៤ម និងទទឹង១២ម បញ្ចូលផងទេ ។

ព្រះគ្រូធម្មាចារ្យបានតាំងមាំក្នុងភេទជាបព្វជិតតរៀងមក រហូតដល់ទទួលអនិច្ចធម្ម ។ ព្រះគ្រូសាងផ្នួសលើកក្រោយនេះបាន២១វស្សាប្លាយ ។ ព្រះគ្រូតែងតែមានព្រះទ័យបរិបូរណ៍ដោយព្រហ្មវិហារធម៌ដល់ពពួកជនគ្រប់ស្រទាប់វណ្ណៈ ហើយនិងជាមគ្គុទ្ទេសជីវិតរបស់ពុទ្ធមាមកជនគ្រប់មជ្ឈដ្ឋាន

www.budinst.gov.kh www.elibraryofcambodia.org

ទាំងពួងផង ជាអគ្គពុទ្ធសាសនូបត្ថម្ភកផង និងជាព្រះជនកនៃកុសលកម្មបទ ១០ផង ។ ព្រោះតែគុណសម្បត្តិ និងបុគ្គលិកលក្ខណៈល្អ កិត្តិនាមបានល្បីរន្ទឺរផ្សាយទៅកាន់ទិសទាំងពួង រហូតដល់បានទទួលឋានៈជាព្រះឧបជ្ឈាយ៍ ដែលសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយឧបេក្ខាសម្ភោជង្ឃិកោ ទេព វង្ស បានប្រទានដោយផ្ទាល់ព្រះហស្តក្នុងព.ស២៥៣៦។

តែអនិច្ចាស្តេចមច្ចុមាកំណាច ម្តេចឡើយមិនខ្លាចហ៊ានមកកាត់
ព្រះជន្មព្រះធម្មាចារ្យដូចសព្វសត្វ លុះសុគតបាត់ទៅស្ងាត់ឈឹង ។
គ្មានចិត្តអាណិតចិត្តមេត្តា គ្មានចិត្តករុណាធ្វើយ៉ាងហ្នឹង
គ្មានគិតយោគយល់ជាទីពឹង ជាទីពុំហ្នឹងយើងរាល់គ្នា ។

ព្រះគ្រូកម្មដ្ឋានាចារ្យ សមថវីរិយោ ម៉ក់ សយ ដែលពុទ្ធមាមកជនបូជាហើយ បានសុគតនាតិថី ថ្ងៃអង្គារ ៦រោច ពេលរសៀល ម៉ោង២ ខែអាសាឍ ឆ្នាំខាល ក្នុងព.ស២៥៤២ ដោយបានបន្សល់ទុកនៅមរតកគុណយ៉ាងច្រើនអនេក សំរាប់បច្ឆាជនជំនាន់ក្រោយប្រត្តិបត្តិតាម ៕

www.budinst.gov.kh www.elibraryofcambodia.org

## ថ្វាយខ្លួនចំពោះព្រះដ៏មានព្រះភាគ

ឱកាស ឥមាហំ ភគវា អត្តភាវំ តុម្ហាកំ បរិច្ចជាមិ ។

ទុតិយម្បិ .......តតិយម្បិ....... ។

សូមគោរព បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គ សូមលះបង់នូវអត្តភាព ថ្វាយចំពោះព្រះអង្គ (ព្រមទាំងព្រះធម៌_ព្រះសង្ឃ) ដើម្បីចំរើននូវ សមថ វិបស្សនាកម្មដ្ឋានធ្វើអោយជាក់ច្បាស់នូវព្រះនិព្វាន ក្នុងឱកាសនេះ

អស់វារៈ២ផងផង...... អស់វារៈ៣ផងផង....... ។

## ថ្វាយខ្លួនចំពោះអាចារ្យ

ឱកាស ឥមាហំ ធម្មាចរិយ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ ។

ទុតិយម្បិ .......តតិយម្បិ....... ។

សូមគោរព បពិត្រព្រះធម្មាចារ្យ (ដ៏ចំរើន ) ខ្ញុំព្រះករុណា សូមលះបង់ នូវអត្តភាពចំពោះលោកម្ចាស់ ដើម្បីចំរើននូវ សមថ វិបស្សនាកម្មដ្ឋាន ធ្វើអោយជាក់ច្បាស់នូវព្រះនិព្វាន ក្នុងឱកាសនេះ

អស់វារៈ២ផងផង...... អស់វារៈ៣ផងផង....... ។

## ក្រៀលគុណ៍ ៤០

នេះឈ្មោះអនត្តា ៥ គឺ ÷

- រូបដូចអ្នកកន្ទៀត
- រូបទទេសោះ

www.budinst.gov.kh www.elibraryofcambodia.org

- រូបសាបសូន្យ
- រូបដូចរបស់ខ្ចីគេ
- រូបមិនមែនជារបស់ខ្លួនឡើយ ។

( ចប់អនត្តា ៥ )

ការរាប់បញ្ចូលក្នុងត្រៃលក្ខណ៍ទាំង ៤០ គឺ ÷

រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ បានទាំងអស់អ្វីទៀត មានអាការ៣២ជាដើម ក៏បញ្ចូលអនិច្ចំ១០ ទុក្ខំ២៥ តាមបញ្ញាចេះចាំ ។

នេះឈ្មោះអនិច្ចំ ១០ គឺ ÷

១_ រូបមិនទៀង
២_ រូបមែងទៅកាន់លោកខាងមុខ
៣_ រូបញាប់ញ័រទៅដោយជំងឺច្រើន
៤_ រូបចំពោះមុខតែងនឹងបែកធ្លាយ
៥_ រូបស្ថិតនៅមិនយូរ
៦_ រូបប្រែប្រួលទៅរកសេចក្តីស្លាប់
៧_ រូបឥតខ្លឹមសារ
៨_ រូបកើតភពណា ប្រាស់ចាកភពនោះ
៩_ រូបមានកុសល និងអកុសលជាហេតុតាក់តែង
១០_ រូបមានសេចក្តីស្លាប់ជាធម្មតា ។

www.budinst.gov.kh www.elibraryofcambodia.org

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

នេះឈ្មោះទុក្ខ ២៥ គឺ ÷

១_រូបលំបាកកាយលំបាកចិត្ត

២_រូបមានរោគច្រើន

៣_រូបមានបូសបមកមរមាស់ច្រើន

៤_រូបមានរោគដូចជាមនុស្សត្រូវកាំសរ

៥_រូបមានចង្រៃបៀតបៀនច្រើន

៦_រូបមានឧបទ្រពរមែងគ្របសង្កត់

៧_រូបមានភ័យច្រើន

៨_រូបមានរោគបង្កើតណែនតឹង

៩_រូបមានរោគរមែងរឹបជាន់

១០_រូបឥតមានអ្វីតទល់នឹងស្តេចមច្ចុរាជ

១១_រូបឥតទីពឹង

១២_រូបឥតទីពឹងពួន

១៣_រូបមានទោសច្រើន

១៤_រូបមានរោគដូចជាបូសកែវនៃទុក្ខ

១៥_រូបមានរោគដូចជាពេជ្ឈឃាតនាំយកអ្នកទោសទៅសំលាប់

១៦_រូបប្រកបទៅដោយអាសវជាគ្រឿងត្រាំ

១៧_រូបច្រឡំទៅដោយមារទាំង ៥

www.budinst.gov.kh www.elibraryofcambodia.org

១៨_រូបមានកើតជាធម្មតា

១៩_រូបមានឈឺជាធម្មតា

២០_រូបមានគ្រាំគ្រាជាធម្មតា

២១_រូបមានអាពាធជាធម្មតា

២២_រូបមានសេចក្ដីសោកស្រណោះអាឡោះអាល័យជាធម្មតា

២៣_រូបមានទូញយំរៀបរាប់ជាធម្មតា

២៤_រូបមានចង្អៀតចង្អល់ចិត្តជាធម្មតា

២៥_រូបមានសេចក្ដីសោកសៅជាធម្មតា ។

( ចប់ទុក្ខ ២៥ )

មិនមែនតែរូបទេ សូម្បី វេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏បំបែកដូចគ្នាដែរ ។

នេះឈ្មោះអនត្តលក្ខណៈ ១២ ពី ÷

១_ រូបំ នសត្តោ រូបនេះមិនមែនសត្វ

២_ រូបំ នជីវោ រូបនេះមិនមែនជីវិត

៣_ រូបំ ននរោ រូបនេះមិនមែនជន

៤_ រូបំ នមាណវោ រូបនេះមិនមែនមាណព

៥_ រូបំ នឥត្ថី រូបនេះមិនមែនស្រី

៦_ រូបំ នបុរិសោ រូបនេះមិនមែនប្រុស

៧_ រូបំ អនត្តា រូបនេះមិនមែនខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

៨_ រូបំ អត្តាបិយំ      រូបនេះមិនមែនជារបស់ខ្លួន

៩_ រូបំ នាហំ      រូបនេះមិនមែនយើង

១០_រូបំ នមម      រូបនេះមិនមែនជារបស់យើង

១១_រូបំ នអញ្ញស្ស      រូបនេះមិនមែនជារបស់អ្នកដទៃ

១២_រូបំ នកស្សចិ      រូបនេះមិនមែនជារបស់អ្នកណា១ឡើយ ។

( ចប់អនត្តលក្ខណៈ ១២ )

រូបនេះឈ្មោះវិបស្សនា១០

រូបអតីតៈ      រូបអនាគត      រូបបច្ចុប្បន្ន      អនិច្ចំ មិនទៀង

សង្ខតំ      រូបនេះកើតមកអំពីបច្ច័យគឺ អវិជ្ជា តណ្ហា

ឧបាទាន      កម្ម      អាហារ      តាក់តែងអោយកើតឡើង

បដិច្ចសមុប្បន្នំ រូបនេះឈ្មោះបដិច្ចសមុប្បាទជាដែនកើតឡើងព្រម រលត់ទៅវិញព្រម ។

_ ខយ ធម្មំ រូបនេះអស់ទៅជាធម្មតា

_ វយ ធម្មំ រូបនេះរលត់សូន្យទៅវិញជាធម្មតា

_ វិរាគ ធម្មំ រូបនេះអ្នកប្រាជ្ញគប្បីនឿយណាយខ្ពើមរអើម

_ និរោធធម្មំ រូបនេះអ្នកប្រាជ្ញគប្បីធ្វើអោយជាក់ច្បាស់ ។

( ចប់រូប )

www.budinst.gov.kh      www.elibraryofcambodia.org

វេទនានេះឈ្មោះវិបស្សនា១០

*.**********

វេទនាអតីត វេទនាអនាគត វេទនាបច្ចុប្បន្ន អនិច្ចំ មិនទៀង សង្ខារតំ វេទនានេះកើតមកអំពីបច្ច័យ គឺ : អវិជ្ជា តណ្ហា ឧបាទាន កម្ម ផស្ស តាក់តែងអោយកើតឡើង ។

បដិច្ចសមុប្បន្នំ វេទនានេះឈ្មោះ បដិច្ចសមុប្បាទ ជាដែនកើតឡើងព្រម រលត់ទៅវិញព្រម ។

_ខយធម្មំ វេទនានេះអស់ទៅជាធម្មតា

_វយធម្មំ វេទនានេះរលត់សូន្យទៅវិញជាធម្មតា

_វិរាគធម្មំ វេទនានេះអ្នកប្រាជ្ញនឿយណាយខ្ពើមរអើម

_និរោធធម្មំ វេទនានេះអ្នកប្រាជ្ញគប្បីធ្វើអោយជាក់ច្បាស់ ។

(ចប់វេទនា )

សញ្ញានេះឈ្មោះវិបស្សនា១០

សញ្ញាអតីត សញ្ញាអនាគត សញ្ញាបច្ចុប្បន្ន អនិច្ចំ មិនទៀង សង្ខារតំ សញ្ញានេះកើតអំពីបច្ច័យ គឺ : អវិជ្ជា តណ្ហា ឧបាទាន កម្ម ផស្ស តាក់តែងអោយកើតឡើង ។

បដិច្ចសមុប្បន្នំ សញ្ញានេះឈ្មោះបដិច្ចសមុប្បាទជាដែនកើតឡើងព្រម រលត់ទៅវិញព្រម ។

_ខយធម្មំ សញ្ញានេះអស់ទៅជាធម្មតា

www.budinst.gov.kh www.elibraryofcambodia.org

_វយធម្មំ សញ្ញានេះរលត់សូន្យទៅវិញជាធម្មតា

_វិបរិណាមធម្មំ សញ្ញានេះអ្នកប្រាជ្ញគប្បីនឿយណាយខ្ពើមរអើម

_និរោធធម្មំ សញ្ញានេះអ្នកប្រាជ្ញគប្បីធ្វើអោយជាក់ច្បាស់ ។

( ចប់សញ្ញា )

សង្ខារនេះឈ្មោះវិបស្សនា១០

សង្ខារអតីត

សង្ខារអនាគត

សង្ខារបច្ចុប្បន្ន

អនិច្ចំ មិនទៀង

សង្ខតំ សង្ខារនេះកើតអំពីបច្ច័យគឺ : អវិជ្ជា តណ្ហា ឧបាទាន កម្ម ផស្ស តាក់តែងអោយកើតឡើង

បដិច្ចសមុប្បន្នំ សង្ខារនេះឈ្មោះបដិសមុប្បាទ ជាដែនកើតឡើងព្រម រលត់ទៅវិញព្រម ។

ខយធម្មំ សង្ខារនេះអស់ទៅជាធម្មតា

វយធម្មំ សង្ខារនេះរលត់សូន្យទៅវិញជាធម្មតា

វិរាគធម្មំ សង្ខារនេះអ្នកប្រាជ្ញគប្បីនឿយណាយខ្ពើមរអើម

និរោធធម្មំ សង្ខារនេះអ្នកប្រាជ្ញគប្បីធ្វើអោយជាក់ច្បាស់ ។

( ចប់សង្ខារ )

www.budinst.gov.kh www.elibraryofcambodia.org

វិញ្ញាណនេះឈ្មោះវិបស្សនា១០

វិញ្ញាណអតីត   វិញ្ញាណអនាគត វិញ្ញានបច្ចុប្បន្ន

អនិច្ចំ   មិនទៀង

សទ្ទាតំ  វិញ្ញាណនេះកើតអំពីបច្ច័យ គឺ : អវិជ្ជា តណ្ហា ឧបាទាន កម្ម នាមរូប តាក់តែងអោយកើតឡើង

បដិច្ចសមុប្បន្នំ វិញ្ញាណនេះឈ្មោះបដិច្ចសមុប្បាទ ជាដែនកើតឡើងព្រម រលត់ទៅវិញព្រម ។

ខយធម្មំ វិញ្ញាណនេះអស់ទៅជាធម្មតា

វយធម្មំ វិញ្ញាណនេះរលត់សូន្យទៅវិញជាធម្មតា

វិរាគធម្មំ វិញ្ញាណនេះអ្នកប្រាជ្ញគប្បីនឿយណាយខ្ពើមរអើម

និរោធធម្មំ វិញ្ញាណនេះអ្នកប្រាជ្ញគប្បីធ្វើអោយជាក់ច្បាស់

( ចប់វិញ្ញាណ )

## រូប នាម

បើបានគិតគូរ ដេក ដើរ ឈរ អង្គុយ  មានរូប នាម គឺ :

ដេក ជារូប   ដឹងថាដេកជានាម

ដើរ ជារូប   ដឹងថាដើរជានាម

ឈរ ជារូប   ដឹងថាឈរជានាម

អង្គុយ ជារូប   ដឹងថាអង្គុយជានាម

www.budinst.gov.kh www.elibraryofcambodia.org

# ហេតុ ផល

បើបានពិតតួរ ដេក ដើរ ឈរ អង្គុយ មានហេតុ ផល ពី :

ដេក ជាហេតុ ដឹងថាដេកជាផល

ដើរ ជាហេតុ ដឹងថាដើរជាផល

ឈរ ជាហេតុ ដឹងថាឈរជាផល

អង្គុយ ជាហេតុ ដឹងថាអង្គុយជាផល ។

# ខន្ធ ៥

រូបក្ខន្ធ ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ ។

បើបានពិតតួរ ដេក ដើរ ឈរ អង្គុយ មានខន្ធ ៥ ពី :

ដេក ជារូបក្ខន្ធ សោយនូវដេក ជាវេទនាខន្ធ កត់សំគាល់នូវដេក ជាសញ្ញាខន្ធ តាក់តែងនូវដេកជាសង្ខារក្ខន្ធ ដឹងច្បាស់ថាដេកជាវិញ្ញាណក្ខន្ធ ។

( រាប់ ដេក ដើរ ឈរ អង្គុយ ដូចគ្នាដែរ ) ។

www.budinst.gov.kh www.elibraryofcambodia.org

# ខន្ធ ៥ មានរូប នាម

| | |
|---|---|
| ១_រូប | បានដល់រូប២៨ ជាធាតុមិនដឹង(រូបក្ខន្ធ) |
| ២_វេទនា | សោយនូវអារម្មណ៍ (ជានាមក្ខន្ធ) |
| ៣_សញ្ញា | កត់សំគាល់នូវអារម្មណ៍ (ជានាមក្ខន្ធ) |
| ៤_សង្ខារ | តាក់តែងនូវអារម្មណ៍ (ជានាមក្ខន្ធ) |
| ៥_វិញ្ញាណ | ដឹងច្បាស់នូវអារម្មណ៍ (ជានាមក្ខន្ធ) |

# កុសលកម្មបថ១០

ដេក ដើរ ឈរ អង្គុយ បើបានគិតគូរមានកុសលកម្មបថ១០ ក្នុងខណៈ អង្គុយស្មៀមភាវនា ពុទ្ធោៗ ហើយពិចារណានូវត្រៃលក្ខណ៍ បើនបានគិតគូរមាន កាយកម្ម៣ វចីកម្ម៤ មនោកម្ម៣ គឺ :

១_មិនធ្វើបាណាតិបាត
២_មិនធ្វើអទិន្នាទាន
៣_មិនធ្វើកាមេ

} នេះឈ្មោះកាយស្អាត៣គឺៈ កាយកម្ម ៣ ជាកាយសុចរិត ។

១_មិនមានមុសាវាទ
២_មិនមានបិសុណាវាទ
៣_មិនមានផរុស្សវាទ
៤_មិនមានសម្ផប្បលាប

} នេះឈ្មោះវចីស្អាត៤ គឺជា វចីកម្ម៤ ជាវចីសុចរិត ។

www.budinst.gov.kh www.elibraryofcambodia.org

១_មិនមានអភិជ្ឈា
២_មិនមានព្យាបាទ
៣_មិនមានមិច្ឆាទិដ្ឋិ

} ចិត្តគឺមនោៗគឺចិត្ត នេះឈ្មោះចិត្តស្អាត ៣ គឺមនោកម្ម៣ជាមនោសុចរិត ។

( ចប់កុសលកម្មបថ១០ )

## អារម្មណ៍របស់វិបស្សនា ឬភូមិបញ្ញា

មាន៦គឺ :

_ខន្ធ៥ អាយតន១២ ធាតុ១៨ ឥន្ទ្រីយ៍២២ អរិយសច្ចៈ៤ បដិច្ចសមុប្បាទ ១២ ( សរុបអារម្មណ៍វិបស្សនាមាន៧៣ ) ។

១_ ខន្ធ ៥ គឺ : រូបក្ខន្ធ១ វេទនាខន្ធ១ សញ្ញាខន្ធ១ សង្ខារក្ខន្ធ១ វិញ្ញាណក្ខន្ធ១ ។

២_ អាយតន ១២ គឺ : អាយតនខាងក្នុង ៦ និងអាយតនខាងក្រៅ ៦ :

_អាយតនខាងក្នុង ៦គឺ : ភ្នែក ១ ត្រចៀក ១ ច្រមុះ ១ អណ្តាត ១ កាយ ១ ចិត្ត ១ ។

_អាយតនខាងក្រៅ ៦ គឺ : រូប ១ សំលេង ១ ក្លិន ១ រស ១ ផោដ្ឋព្វ ១ ធម្មារម្មណ៍ ១ ។

៣_ ធាតុ ១៨ គឺ :

_ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ

www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| -សោតធាតុ | សទ្ទធាតុ | សោតវិញ្ញាណធាតុ |
| -ឃានធាតុ | គន្ធធាតុ | ឃានវិញ្ញាណធាតុ |
| -ជិវ្ហាធាតុ | រសធាតុ | ជិវ្ហាវិញ្ញាណធាតុ |
| -កាយធាតុ | ផោដ្ឋព្វធាតុ | កាយវិញ្ញាណធាតុ |
| -មនោធាតុ | ធម្មធាតុ | មនោវិញ្ញាណធាតុ |

៤_ឥន្ទ្រីយ៍២២គឺ :

ចក្ខុន្ទ្រីយ៍ សោតិន្ទ្រីយ៍ ឃានិន្ទ្រីយ៍ ជិវ្ហិន្ទ្រីយ៍
កាយិន្ទ្រីយ៍ មនិន្ទ្រីយ៍ ឥត្ថិន្ទ្រីយ៍ បុរិសិន្ទ្រីយ៍
ជីវិតិន្ទ្រីយ៍ សុខិន្ទ្រីយ៍ ទុក្ខិន្ទ្រីយ៍ សោមនស្សិន្ទ្រីយ៍
ទោមនស្សិន្ទ្រីយ៍ ឧបេក្ខិន្ទ្រីយ៍ សទ្ធិន្ទ្រីយ៍ វិរិយិន្ទ្រីយ៍
សតិន្ទ្រីយ៍ សមាធិន្ទ្រីយ៍ បញ្ញិន្ទ្រីយ៍ អនញ្ញតញ្ញស្សាមីតិន្ទ្រីយ៍
អញ្ញិន្ទ្រីយ៍ អញ្ញាតាវិន្ទ្រីយ៍ ។

៥_អរិយសច្ចៈ ៤ គឺ :

ទុក្ខអរិយសច្ចៈ ១ សមុទយអរិយសច្ចៈ ១
និរោធអរិយសច្ចៈ ១ មគ្គអរិយសច្ចៈ ១

៦_បដិច្ចសមុប្បាទ ១២ គឺ :

| | | |
|---|---|---|
| អវិជ្ជា | ជាបច្ច័យនាំអោយកើត | សង្ខារ |
| សង្ខារ | ជាបច្ច័យនាំអោយកើត | វិញ្ញាណ |

www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| វិញ្ញាណ | ជាបច្ច័យនាំអោយកើត | នាមរូប |
| នាមរូប | ជាបច្ច័យនាំអោយកើត | សឡាយតន |
| សឡាយតន | ជាបច្ច័យនាំអោយកើត | ផស្ស |
| ផស្ស | ជាបច្ច័យនាំអោយកើត | វេទនា |
| វេទនា | ជាបច្ច័យនាំអោយកើត | តណ្ហា |
| តណ្ហា | ជាបច្ច័យនាំអោយកើត | ភព |
| ភព | ជាបច្ច័យនាំអោយកើត | ជាតិ |
| ជាតិ | ជាបច្ច័យនាំអោយកើត | ជរាមរណៈ |

| | | |
|---|---|---|
| ជរាមរណៈ | មាន ជាតិ | ជាហេតុជាដែនកើត |
| ជាតិ | មាន ភព | ជាហេតុជាដែនកើត |
| ភព | មាន ឧបាទាន | ជាហេតុជាដែនកើត |
| ឧបាទាន | មាន តណ្ហា | ជាហេតុជាដែនកើត |
| តណ្ហា | មាន វេទនា | ជាហេតុជាដែនកើត |
| វេទនា | មាន ផស្ស | ជាហេតុជាដែនកើត |
| ផស្ស | មាន សឡាយតន | ជាហេតុជាដែនកើត |
| សឡាយតន | មាន នាមរូប | ជាហេតុជាដែនកើត |
| នាមរូប | មាន វិញ្ញាណ | ជាហេតុជាដែនកើត |

www.budinst.gov.kh www.elibraryofcambodia.org

វិញ្ញាណ មាន សង្ខារ ជាហេតុជាដែនកើត

សង្ខារ មាន អវិជ្ជា ជាហេតុជាដែនកើត

( ចប់ភូមិបញ្ហា )

**ខន្ធ ៥ មានត្រៃលក្ខណ៍**

- ខន្ធ ៥មិនទៀង ប្រែប្រួល ឈ្មោះថាអនិច្ចលក្ខណៈ
- ខន្ធ ៥ប្រកបទៅដោយទុក្ខទាំង ១២កង ឈ្មោះទុក្ខលក្ខណៈ
- ខន្ធ ៥ ចេះតែអស់ទៅ សូន្យទៅ ឈ្មោះថាអនត្តលក្ខណៈ

(ចប់ )

**សុភាសិតព្រះគ្រូសមថវីរិយោ ប៉ក់ . សយ**

- ធ្វើអ្វីៗត្រូវមានខ្នាត បើចង់ស្អាតត្រូវធ្វើដោយយកចិត្តទុកដាក់
- មនុស្សកុំមើលងាយមនុស្ស បើមើលមិនធ្លុះកុំអាលទាយ
- មនុស្សកុំទុកចិត្តមនុស្ស បើមើលមិនធ្លុះកុំអាលជឿ
- បើទាបអោយទាប ដូចជាក្រណាត់ជូតជើង
- បើតូច អោយតូចដូចចុងម្ជុល
- បើធំអោយធំដូចដើមគរ
- អាចារ្យស្មោះត្រង់ ព្រះសង្ឃបរិសុទ្ធ វត្តរុងរឿង
- ពុទ្ធបរិស័ទស្មោះត្រង់ ព្រះសង្ឃទ្រទ្រង់វិន័យ

សាសនាព្រះជិនស្រី រុងរឿងរហូត

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

- បើផឹកស្រាអោយស្គាល់ដបស្រា បើធ្វើអាចារ្យអោយស្គាល់សង្ឃវត្ត
- បើស្រឡាញ់ខ្លួនកុំពួនដេក ស្អប់ដំណេកស្រឡាញ់ព្រះ
- ស្អប់ខ្លួនពួកដេក ស្រឡាញ់ដំណេកស្អប់ព្រះ
- បើនៅអោយគេស្រឡាញ់ ដើរចេញអោយគេអាណិត
- យកពុតកុកសាប់ កុំយកតំរាប់កុក ស
  យកពូជឫស្សីល្អ កុំយកកន្ទ្រាញស្ងាយ
- បើបាននំផ្អែម កុំភ្លេចស្ករ
- អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ
  អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនៅសំប៉ាន ។

www.budinst.gov.kh www.elibraryofcambodia.org

# គិរិមានន្ទសូត្រ

ឯវម្មេ សុតំ (សូត្រនេះឈ្មោះគិរិមានន្ទសូត្រ)គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ សម័យ១ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី តេន ខោ បន សមយេន អាយស្មា គិរិមានន្ទោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ក៏ក្នុងសម័យនោះឯង ព្រះគិរិមានន្ទដ៏មានអាយុ លោកមានអាពាធ ប្រកបដោយទុក្ខវេទនាជាជម្ងឺធ្ងន់

អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ គ្រានោះឯង ព្រះអានន្ទត្ថេរដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ

ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ព្រះអានន្ទត្ថេរដ៏មានអាយុ កាលអង្គុយទីដ៏សមគួរហើយក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា

អាយស្មា ភន្តេ គិរិមានន្ទោ អាពាធិកោ ទុក្ខិតោពាឡ្ហគិលានោ បពិត្រព្រះអង្គដ៏ចំរើន គិរិមានន្ទដ៏មានអាយុ មានអាពាធ ប្រកបដោយទុក្ខវេទនា

www.budinst.gov.kh www.elibraryofcambodia.org

ជាជម្ងឺធ្ងន់

សាធុ ភន្តេ ភគវា យេនាយស្មា គិរិមានន្ទោ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ព្រះមេត្តាអនុគ្រោះ (ចំពោះព្រះគិរិមានន្ទ)សូមស្តេចយាងចូលទៅ ត្រង់កន្លែងដែលគិរិមានន្ទដ៏មានអាយុអាស្រ័យនៅ ។

(ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់តបថា )

សចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឧបសង្កមិត្វា ទស សញ្ញា ភាសេយ្យាសិ ម្នាលអានន្ទប្រសិនបើអ្នកចូលទៅកាន់សំណាក់នៃគិរិមានន្ទភិក្ខុ ហើយសំដែងប្រាប់នូវសញ្ញាទាំង ១០ប្រការ

ឋានំ ខោ បនេតំ វិជ្ជតិ យំ គិរិមានន្ទស្ស ភិក្ខុនោ ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យ ដំណើរនេះជាហេតុនឹងឱ្យអាពាធរបស់គិរិមានន្ទភិក្ខុនោះ បានរម្ងាប់សះស្បើយទៅដោយ១រំពេច ព្រោះគិរិមានន្ទភិក្ខុបានស្តាប់នូវសញ្ញាទាំង ១០ប្រការ

កតមា ទស សញ្ញា សញ្ញា ១០ប្រការនោះដូចម្តេចខ្លះ ?

អនិច្ចសញ្ញា អនត្តសញ្ញា អសុភសញ្ញា អាទីនវសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា សព្វលោកេ អនភិរតសញ្ញា សព្វសង្ខារេសុ អនិដ្ឋសញ្ញា អានាបានស្សតិ(សញ្ញា១០ប្រការនោះ ) គឺអនិច្ចសញ្ញា១ អនត្តៈសញ្ញា១ អសុភសញ្ញា១ អាទីនវសញ្ញា១ បហានសញ្ញា១ វិរាគសញ្ញា១ និរោធសញ្ញា១ សព្វលោកេ អនភិរតសញ្ញា១ សព្វសង្ខារេសុ អនិដ្ឋសញ្ញា១ អានាបាណស្សតិ១

www.budinst.gov.kh www.elibraryofcambodia.org

# គិរិមានន្ទសុត្តំ

ឯវម្មេ សុតំ (សូត្រនេះឈ្មោះគិរិមានន្ទសូត្រ)គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ សម័យ១ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី តេន ខោ បន សមយេន អាយស្មា គិរិមានន្ទោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ក៏ក្នុងសម័យនោះឯង ព្រះគិរិមានន្ទដ៏មានអាយុ លោកមានអាពាធ ប្រកបដោយទុក្ខវេទនាជាជម្ងឺធ្ងន់

អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ គ្រានោះឯង ព្រះអានន្ទត្ថេរដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ

ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ព្រះអានន្ទត្ថេរដ៏មានអាយុ កាលអង្គុយទីដ៏សមគួរហើយក៏ក្រាបបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា

អាយស្មា ភន្តេ គិរិមានន្ទោ អាពាធិកោ ទុក្ខិតោពាឡ្ហគិលានោ បពិត្រព្រះអង្គដ៏ចំរើន គិរិមានន្ទដ៏មានអាយុ មានអាពាធ ប្រកបដោយទុក្ខវេទនា

www.budinst.gov.kh www.elibraryofcambodia.org

ជាជម្ងឺធ្ងន់

សាធុ ភន្តេ ភគវា យេនាយស្មា គិរិមានន្ទោ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ព្រះមេត្តាអនុគ្រោះ (ចំពោះព្រះគិរីមានន្ទ) សូមស្តេចយាងចូលទៅ ត្រង់កន្លែងដែលគិរីមានន្ទដ៏មានអាយុអាស្រ័យនៅ ។

(ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់តបថា )

សចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឧបសង្កមិត្វា ទស សញ្ញា ភាសេយ្យាសិ ម្នាលអានន្ទប្រសិនបើអ្នកចូលទៅកាន់សំណាក់នៃគិរីមានន្ទភិក្ខុ ហើយសំដែងប្រាប់នូវសញ្ញាទាំង ១០ប្រការ

ឋានំ ខោ បនេតំ វិជ្ជតិ យំ គិរិមានន្ទស្ស ភិក្ខុនោ ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យ ដំណើរនេះជាហេតុនឹងឱ្យអាពាធរបស់គិរីមានន្ទភិក្ខុនោះ បានរម្ងាប់សះស្បើយទៅដោយ១រំពេច ព្រោះគិរីមានន្ទភិក្ខុបានស្តាប់នូវសញ្ញាទាំង ១០ប្រការ

កតមា ទស សញ្ញា សញ្ញា ១០ប្រការនោះដូចម្តេចខ្លះ ?

អនិច្ចសញ្ញា អនត្តសញ្ញា អសុភសញ្ញា អាទីនវសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា សព្វលោកេ អនភិរតសញ្ញា សព្វសង្ខារេសុ អនិដ្ឋសញ្ញា អានាបានស្សតិ (សញ្ញា១០ប្រការនោះ ) គឺអនិច្ចសញ្ញា១ អនត្តៈសញ្ញា១ អសុភសញ្ញា១ អាទីនវសញ្ញា១ បហានសញ្ញា១ វិរាគសញ្ញា១ និរោធសញ្ញា១ សព្វលោកេ អនភិរតសញ្ញា១ សព្វសង្ខារេសុ អនិដ្ឋសញ្ញា១ អានាបាណស្សតិ១

www.budinst.gov.kh www.elibraryofcambodia.org

កតមា ចានន្ទ អនិច្ចសញ្ញា  ម្នាលអានន្ទ អនិច្ចសញ្ញា ( នោះ ) ដូចម្តេច ?

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ  ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា

រូបំ អនិច្ចំ រូបមិនទៀង

វេទនា អនិច្ចា វេទនាមិនទៀង

សញ្ញា អនិច្ចា សញ្ញាមិនទៀង

សង្ខារា អនិច្ចា សង្ខារទាំងឡាយមិនទៀង

វិញ្ញាណំ អនិច្ចន្តិ វិញ្ញាណមិនទៀង

ឥតិ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ អនិច្ចានុបស្សី វិហរតិ ភិក្ខុពិចារណាឃើញរឿយៗ ថាមិនទៀង ក្នុងឧបាទានក្ខន្ធទាំងឡាយ ៥ នេះ ដោយប្រការដូច្នេះ

អយំ វុច្ចតានន្ទ អនិច្ចសញ្ញា ម្នាលអានន្ទនេះហើយដែលតថាគតហៅថា អនិច្ចសញ្ញា ។

កតមា ចានន្ទ អនត្តសញ្ញា ម្នាលអានន្ទ អនត្តសញ្ញា( នោះ)ដូចម្តេច?

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា

www.budinst.gov.kh www.elibraryofcambodia.org

ចក្ខុំ អនត្តា ភ្នែក មិនមែនជារបស់ខ្លួន

រូបា[១] អនត្តា រូបទាំងឡាយ មិនមែនជារបស់ខ្លួនទេ

សោតំ អនត្តា ត្រចៀក មិនមែជារបស់ខ្លួនទេ

សទ្ទា អនត្តា សម្លេងទាំងឡាយ មិនមែនជារបស់ខ្លួនទេ

ឃានំ អនត្តា ច្រមុះ មិនមែនជារបស់ខ្លួនទេ

គន្ធា អនត្តា ក្លិនទាំងឡាយ មិនមែនជារបស់ខ្លួនទេ

ជិវ្ហា អនត្តា អណ្តាត មិនមែនជារបស់ខ្លួនទេ

រសា អនត្តា រសទាំងឡាយ មិនមែនជារបស់ខ្លួនទេ

កាយោ អនត្តា កាយ មិនមែនជារបស់ខ្លួនទេ

ផោដ្ឋព្វា អនត្តា ផ្សព្វទាំងឡាយ មិនមែនជារបស់ខ្លួនទេ

មនោ អនត្តា ចិត្ត មិនមែនជារបស់ខ្លួនទេ

ធម្មា អនត្តា ធមិទាំងឡាយ ក៏មិនមែនជារបស់ខ្លួនទេ

ឥតិ ឥមេសុ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ អនត្តានុបស្សី វិហរតិ ភិក្ខុពិចារណាឃើញរឿយៗថា មិនមែនជារបស់ខ្លួនក្នុងអាយតនខាងក្នុង៦និងអាយតនខាងក្រៅ៦ នេះដោយប្រការដូច្នេះ

អយំ វុច្ចតានន្ទ អនត្តសញ្ញា ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា អនត្តសញ្ញា ។

---

១_ធ្លាប់សូត្របកថា រូបំ តែបានពិនិត្យក្នុងគម្ពីរច្រើន ឃើញថា រូបា ដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

កតមា ចានន្ទ អសុភសញ្ញា ម្នាលអានន្ទ អសុភសញ្ញា(នោះ)ដូចម្តេច?

ឥធានន្ទ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយនេះឯង ខាងលើអំពីផ្ទៃនៃបាទជើងឡើងទៅ ខាងក្រោមអំពីចុងនៃសក់ចុះមក ពាសជុំវិញដោយស្បែក ពេញដោយគ្រឿងមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា

អត្ថិ ឥមស្មឹ កាយេ មានក្នុងរូបកាយនេះ

កេសា សក់ទាំងឡាយ លោមា រោមទាំងឡាយ នខា ក្រចកទាំងឡាយ ទន្តា ធ្មេញទាំងឡាយ តចោ ស្បែក មំសំ សាច់ នហារូ សរសៃទាំងឡាយ អដ្ឋី ឆ្អឹងទាំងឡាយ អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង វក្កំ ទាច ហទយំ បេះដូង យកនំ ថ្លើម កិលោមកំ វាវ បិហកំ ក្រពះ បប្ផាសំ សួត អន្តំ ពោះវៀនធំ អន្តគុណំ ពោះវៀនតូច ឧទរិយំ អាហារថ្មី ករីសំ អាហារចាស់ បិត្តំ ប្រមាត់ សេម្ហំ ស្លេស្ម បុព្វោ ខ្ទុះ លោហិតំ ឈាម សេទោ ញើស មេទោ ខ្លាញ់ខាប់ អស្សុ ទឹកភ្នែក វសា ខ្លាញ់រាវ ខេឡោ ទឹកមាត់ សិង្ឃាណិកា ទឹកសម្បោរ លសិកា ទឹករំអិលមុត្តន្តិ ទឹកមូត្រ ឥតិ ឥមស្មឹ កាយេ អសុភានុបស្សី វិហរតិ ភិក្ខុពិចារណាឃើញរឿយៗថា ជាគ្រឿងមិនស្អាតក្នុងរូបកាយនេះ ដោយប្រការដូច្នេះ

អយំ វុច្ចតានន្ទ អសុភសញ្ញា ម្នាលអានន្ទ នេះហើយ ដែលតថាគតហៅថា អសុភសញ្ញា ។

www.budinst.gov.kh www.elibraryofcambodia.org

កតមា ចានន្ទ អាទីនវសញ្ញា ម្នាលអានន្ទ អាទីនវសញ្ញា (នោះ) ដូម្តេច ?

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា

ពហុទុក្ខោ ខោ អយំ កាយោ ពហុអាទីនវោតិ រូបកាយនេះមានទុក្ខច្រើន មានទោសច្រើនមែនពិត

ឥតិ ឥមស្មឹ កាយេ វិវិធា អាពាធា ឧប្បជ្ជន្តិ អាពាធគឺជម្ងឺដម្កាត់ទាំងឡាយផ្សេងៗតែងកើតឡើងក្នុងកាយនេះដូច្នេះ

សេយ្យថីទំ អាពាធនោះ ដូម្តេចខ្លះ ?

ចក្ខុរោគោ គឺរោគនៅក្នុងភ្នែក សោតរោគោ រោគក្នុងត្រចៀក ឃានរោគោ រោគក្នុងច្រមុះ ជីវ្ហារោគោ រោគក្នុងអណ្តាត កាយរោគោ រោគក្នុងកាយ សីសរោគោ រោគក្នុងក្បាល កណ្ណរោគោ រោគខាងក្រៅត្រចៀក មុខរោគោ រោគក្នុងមាត់ ទន្តរោគោ រោគត្រង់គល់ធ្មេញ កាសោ រោគក្អួត សាសោ រោគហឺត បិនាសោ រោគក្រៅច្រមុះ ឌហោ រោគក្តៅក្រហាយ ជរោ រោគស្គាំងស្គម កុច្ឆិរោគោ រោគក្នុងផ្ទៃ មុច្ឆារោគោ រោគខ្យល់ចាប់ វិលមុខ បក្ខន្ទិកា រោគធ្លាក់ឈាម សុលា រោគចុកសៀត វិសូចិកា រោគចុះរាគ កុដ្ឋំ រោគឃ្លង់ គណ្ឌោ រោគពក កិលាសោ រោគកស្រែង សោសោរោគរីងរៃ អបមារោ រោគឆ្កួតជ្រូក ទទ្ទុ រោគជំនួចពិស កណ្ឌុ រោគរមាស់ កច្ឆុ

www.budinst.gov.kh www.elibraryofcambodia.org

រោគកមក្រិន រខសា រោគកញ្ជ្រិល វិតច្ឆិកា រោគកមរលាយ លោហិតំ រោគឈាម បិត្តំ រោគប្រមាត់ មធុមេហោ រោគប្រមេះទឹកបាយ អំសា រោគឫសដូងបាតដុះជុំវិញទ្វារធំ បិឡកា រោគរលកកែវ ភគន្ទលា រោគឫសដូងបាតដុះខាងក្នុង(១) បិត្តសមុដ្ឋានា អាពាធា អាពាធកើតអំពីប្រមាត់ សេម្ហសមុដ្ឋានា អាពាធកើតអំពីស្លេស្ម វាតសមុដ្ឋានា អាពាធា អាពាធកើតឡើងអំពីខ្យល់ សន្និបាតិកាអាពាធា អាពាធកើតអំពីសន្និបាត គឺកំរើកប្រមាត់ស្លេស្មនិងខ្យល់ប្រជុំគ្នា ឧតុបរិណាមជា អាពាធា អាពាធកើតអំពីរដូវប្រែប្រួល វិសមបរិហារជា អាពាធា អាពាធកើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើគ្នា ឱបក្កមិកា អាពាធា អាពាធាកើតអំពីសេចក្តីព្យាយាម (របស់អ្នកឯទៀត ) មានចាប់ចងវាយកាប់ជាដើម កម្មវិបាកជាអាពាធា អាពាធកើតអំពីវិបាករបស់កម្ម សីតំ អាពាធកើតអំពីត្រជាក់ ឧណ្ហំ អាពាធកើតអំពីក្តៅ ជិឃច្ឆា អាពាធកើតអំពីសេចក្តីឃ្លាន បិបាសា អាពាធកើតអំពីសេចក្តីស្រេក ឧច្ចារោ អាពាធកើតអំពីឧច្ចារ បស្សាវោតិ អាពាធកើតអំពីបស្សាវ ។

ឥតិ ឥមស្មឹ កាយេ អាទីនវានុបស្សី វិហរតិ ភិក្ខុពិចារណាឃើញរឿយៗថា ជាទោសក្នុងរូបកាយនេះ ដោយប្រការដូច្នេះ

អយំ វុច្ចតានន្ទ អាទីនវសញ្ញា ម្នាលអានន្ទ នេះហើយដែល

---

១_អដ្ឋកថាប្រាប់ថា ឫសដូងបាតដែលដុះខាងក្នុង ត្រង់ចន្លោះទ្វារធំ និងទ្វារតូច

www.budinst.gov.kh www.elibraryofcambodia.org

ពថាគត ហៅថា អាទីនវសញ្ញា ។

កតមា ចានន្ទ បហានសញ្ញា ម្នាលអានន្ទ បហានសញ្ញា(នោះ) ដូចម្តេច?

ឥធានន្ទ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មិនតាំងចិត្តទទួលគឺលះបង់បន្ទោបង់ ធ្វើឱ្យវិនាស ធ្វើមិនឱ្យកើតតទៅទៀតនូវកាមវិតក្ក គឺសេចក្តីត្រិះរិះក្នុងកាមដែលកើតឡើងហើយ

ឧប្បន្នំ ព្យាបាទវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ មិនតាំងចិត្តទទួល គឺលះបង់បន្ទោបង់ ធ្វើអោយវិនាស ធ្វើមិនអោយកើតតទៅទៀត នូវព្យាបាទវិតក្ក គឺសេចក្តីត្រិះរិះក្នុងកិរិយាញុំាងសត្វដទៃឱ្យវិនាស ដែលកើតឡើងហើយ

ឧប្បន្នំ វិហឹសាវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ មិនតាំងចិត្តទទួល គឺលះបង់បន្ទោបង់ ធ្វើអោយវិនាស ធ្វើមិនអោយកើតតទៅទៀត នូវវិហឹសាវិតក្ក គឺសេចក្តីត្រិះរិះក្នុងការបៀតបៀនសត្វ ដែលកើតឡើងហើយ

ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ មិនតាំងចិត្តទទួល គឺលះបង់បន្ទោបង់ ធ្វើអោយវិនាស ធ្វើមិនអោយកើតតទៅទៀត នូវធម៌ដែលជាបាបអកុសល ដែលកើតឡើងហើយរឿយៗ ។

អយំ វុច្ចតានន្ទ បហានសញ្ញា ម្នាលអានន្ទ នេះហើយដែលតថាគត

www.budinst.gov.kh www.elibraryofcambodia.org

ហៅថា បហានសញ្ញា ។

កតមា ចានន្ទ វិរាគសញ្ញា ម្នាលអានន្ទ វិរាគសញ្ញា(នោះ)ដូចម្ដេច?

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្ដី នៅទៀបគល់ឈើក្ដី នៅក្នុងផ្ទះដ៏ស្ងាត់ក្ដី ពិចារណាឃើញដូច្នេះថា

ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និព្វានន្តិ វិរាគធម៌ គឺព្រះនិព្វានឯណា ដែលរម្ងាប់បង់នូវសង្ខារទាំងពួង លះបោលនូវកិលេសទាំងពួង អស់តណ្ហាហើយ វិរាគធម៌ គឺព្រះនិព្វានន៎ះជាគុណជាតស្ងប់រម្ងាប់,វិរាគធម៌គឺព្រះនិព្វានន៎ះជាគុណជាតដ៏ឧត្តម

អយំ វុច្ចតានន្ទ វិរាគសញ្ញា ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា វិរាគសញ្ញា ។

កតមា ចានន្ទ និរោធសញ្ញា ម្នាលអានន្ទ និរោធសញ្ញា (នោះ) ដូចម្ដេច

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្ដីនៅទៀបគល់ឈើក្ដី នៅក្នុងផ្ទះដ៏ស្ងាត់ក្ដី ពិចារណាឃើញដូច្នេះថា

ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ

សព្វូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ និរោធោ និព្វានន្តិ និរោធធម៌ គឺព្រះ

www.budinst.gov.kh www.elibraryofcambodia.org

និព្វានឯណា ដែលរម្ងាប់បង់នូវសង្ខារទាំងពួង លះចោលនូវកិលេសទាំងពួង អស់តណ្ហាហើយ និរោធធម៌ គឺព្រះនិព្វាន*៖ ជាគុណជាតដ៏ឧត្តម

អយំ វុច្ចតានន្ទ និរោធសញ្ញា ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា និរោធសញ្ញា ។

កតមា ចានន្ទ សព្វលោកេ អនភិរតសញ្ញា ម្នាលអានន្ទ សព្វលោកេ អនភិរតសញ្ញា (នោះ) ដូចម្ដេច ?

ឥធានន្ទ ភិក្ខុ យេ លោកេ ឧបាយុបាទានា ចេតសោអធិដ្ឋានាភិនិវេសានុសយា តេ បជហន្តោ វិរមតិ ន ឧបាទិយន្តោ ម្នាលអានន្ទឧបាយគឺតណ្ហានិងទិដ្ឋិឯណា ឧបាទានគឺសេចក្ដីប្រកាន់មាំឯណា អភិនិវេស គឺសស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ជាទីអាស្រ័យនៅនៃចិត្តឯណា អនុស័យគឺកិលេសដែលដេកនៅរឿយៗ ក្នុងសត្តសន្តានឯណា ក្នុងលោក ភិក្ខុក្នុងសាសនានេះ កាលបើលះបង់នូវបាបធម៌ទាំងនោះ (ដោយតទង្គាទិបហាន) មិនបានប្រកាន់មាំដោយចិត្តក៏រមែងវៀរ (ចាកបាបធម៌ទាំងនោះបាន)

អយំ វុច្ចតានន្ទ សព្វលោកេ អនភិរតសញ្ញា ម្នាលអានន្ទ នេះហើយដែលតថាគត ហៅថាសព្វលោកេ អនភិរតសញ្ញា ។

កតមា ចានន្ទ សព្វសង្ខារេសុ អនិច្ចសញ្ញា ម្នាលអានន្ទសព្វសង្ខារេសុ អនិច្ចសញ្ញា (នោះ) ដូចម្ដេច ?

ឥធានន្ទ ភិក្ខុ សព្វសង្ខារេហិ អដ្ដីយតិ ហរាយតិ ជិគុច្ឆតិ ម្នាលអានន្ទ ភិក្ខុក្នុងសាសនា នឿយណាយធុញទ្រាន់ស្អប់ខ្ពើមសង្ខារទាំងពួង

www.budinst.gov.kh www.elibraryofcambodia.org

អយំ ទុច្ចតានន្ទ សព្វសង្ខារេសុ អនិច្ចសញ្ញា ម្នាលអានន្ទ នេះហើយ ដែលតថាគតហៅថា សព្វសង្ខារេសុ អនិច្ចសញ្ញា[១] ។

កតមា ចានន្ទ អានាបាណស្សតិ ម្នាលអានន្ទ អានាបាណស្សតិ (នោះ)ដូចម្តេច ?

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី អង្គុយផ្គត់ភ្នែន តាំងកាយឱ្យត្រង់ ដំកល់ស្មារតីឱ្យឆ្ពោះត្រង់ទៅរកព្រះកម្មដ្ឋាន

សោ សតោវ អស្សសតិ ភិក្ខុនោះមានស្មារតីចាំជាក់ដកដង្ហើមចេញ

សតោ បស្សសតិ មានស្មារតីចាំជាក់ ដកដង្ហើមចូល

ទីឃំ វា អស្សសន្តោ ទីឃំ អស្សសិស្សាមីតិ បជានាតិ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើបចេញវែង

ទីឃំ វា បស្សសន្តោ ទីឃំ បស្សសិស្សាមិតិ បជានាតិ កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង

រស្សំ វា អស្សសន្តោ រស្សំ អស្សសិស្សាមីតិ បជានាតិ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី

---

១_ ប្រែថាសេចក្តីសំគាល់ក្នុងកិរិយាមិនប្រាថ្នា ឬមិនលុះលង់ទៅក្នុងសង្ខារទាំងពួង

www.budinst.gov.kh www.elibraryofcambodia.org

រស្សំ វា បស្សសន្តោ រស្សំ បស្សសិស្សាមីតិ បជានាតិ កាលដក ដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី

សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សា(១) ដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវកាយ(២)គឺដង្ហើមចេញទាំងអស់ ឱ្យប្រាកដ ទើបដកដង្ហើមចេញ

សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សា ដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវកាយ(៣) គឺដង្ហើមចូលទាំងអស់ឱ្យប្រាកដ ទើបដកង្ហើមចូល

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នករម្ងាប់នូវកាយសង្ខារ(៤) គឺដង្ហើមចេញ ទើបដក ង្ហើមចេញ

បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នករម្ងាប់នូវកាយសង្ខារ (៥) គឺដង្ហើមចូលទើបដកង្ហើមចូល

---

១_អដ្ឋកថា ថា ព្យាយាម ។ ២_អដ្ឋកថា ពន្យល់ថាធ្វើខាងដើមខាង កណ្ដាលនិងទីបំផុតនៃកាយគឺដង្ហើមចេញទាំងអស់ឱ្យបានប្រាកដ ។ ២_ អដ្ឋកថាពន្យល់ធ្វើខាងដើម ខាងកណ្ដាល និងទីបំផុតនៃកាយ គឺដក ដង្ហើមចូលទាំងអស់អោយប្រាកដ ។ ៤_៥ អដ្ឋកថាពន្យល់ថាកាយសង្ខារ ដ៏គ្រោតគ្រាត ។

www.budinst.gov.kh www.elibraryofcambodia.org

បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចេញ

បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចូល

សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវសេចក្តីសុខ ទើបដកដង្ហើមចេញ

សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញ នឹងជាអ្នកដឹងច្បាស់នូវសេចក្តីសុខ ទើបដកដង្ហើមចូល

ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថាអាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ ទើបដកដង្ហើមចេញ

ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថាអាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល

បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថាអាត្មាអញនឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ (១) ទើបដកដង្ហើមចេញ

បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថាអាត្មាអញនឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល

ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចេញ

---

១_ចិត្តសង្ខារ គឺវេទនាខន្ធនិងសញ្ញាខន្ធ ។

www.budinst.gov.kh www.elibraryofcambodia.org

ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចូល

អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថាអាត្មាអញនឹងធ្វើចិត្តរីករាយ ទើបដកដង្ហើមចេញ

អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថាអាត្មាអញនឹងធ្វើចិត្តរីករាយ ទើបដកដង្ហើមចូល

សមាធហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងដំកល់ចិត្តឱ្យស្មើក្នុងអារម្មណ៍ ទើបដកដង្ហើមចេញ

សមាធហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងដំកល់ចិត្តឱ្យស្មើក្នុងអារម្មណ៍ ទើបដកដង្ហើមចូល

វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងដោះចិត្តអោយរួចចាកនីវរណធម៌ជាដើម (១) ទើបដកដង្ហើមចេញ

---

១-អដ្ឋកថា ពន្យល់ថា ភិក្ខុដោះចិត្តឱ្យរួចចាកនីវរណធម៌ដោយបឋមជ្ឈានឱ្យរួចចាកវិតក្កនិងវិចារដោយទុតិយជ្ឈាន, ឱ្យរួចចាកបីតិដោយតតិយជ្ឈាន, ឱ្យរួចចាកសុខនិងទុក្ខដោយចតុត្ថជ្ឈាន, ឱ្យរួច ចាកនិច្ចសញ្ញាដោយអនិច្ចានុបស្សនា, ឱ្យរួចចាកសុខសញ្ញាដោយទុក្ខានុបស្សនា ឱ្យរួចចាកអត្តសញ្ញាដោយអនត្តានុបស្សនា, ឱ្យរួចចាកនន្ទិដោយនិព្វិទានុបស្សនាឱ្យរួចចាករាគដោយវិរាគានុបស្សនា ឱ្យរួចចាកសមុទយដោយនិរោធានុបស្សនាឱ្យរួចចាកឧបាទានដោយបដិនិស្សគ្គានុបស្សនា ។

www.budinst.gov.kh www.elibraryofcambodia.org

ទិរោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងដោះចិត្តឱ្យរួចចាកនីវរណធម៌ជាដើម ទើបដកដង្ហើមចូល ។

អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវបញ្ចក្ខន្ធថាមិនទៀង ទើបដកដង្ហើមចេញ។

អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវបញ្ចក្ខន្ធថាមិនទៀង ទើបដកដង្ហើមចូល

វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ដែលប្រាសចាករាគ ទើបដកដង្ហើមចេញ

វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ដែលប្រាសចាករាគ ទើបដកដង្ហើមចូល

និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ដែលរំលត់បង់នូវកងទុក្ខ ទើបដកដង្ហើមចេញ ។

និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ដែលរំលត់បង់នូវកងទុក្ខ ទើបដកដង្ហើមចូល ។

បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ជាគ្រឿងលះចោលនូវកិលេស ទើបដកដង្ហើមចេញ។

www.budinst.gov.kh www.elibraryofcambodia.org

បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាដូរច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ជាគ្រឿងលះចោលនូវកិលេស ទើបដកដង្ហើមចូល។

អយំ វុច្ចតានន្ទ អានាបាណស្សតិ ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា អានាបាណស្សតិ ។

សចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឧបសង្កមិត្វា ឥមា ទស សញ្ញា ភាសេយ្យាសិ ម្នាលអានន្ទ បើអ្នកចូលទៅ (កាន់សំណាក់) នៃគិរិមានន្ទភិក្ខុហើយ គប្បីសំដែងសញ្ញាទាំងឡាយ ១០ប្រការនេះ ។ ឋានំ ខោ បនេតំ វិជ្ជតិ យំ គិរិមានន្ទស្ស ភិក្ខុនោ ឥមា ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យាតិ ដំណើរនេះ ជាហេតុនឹងឱ្យអាពាធរបស់គិរិមានន្ទ ភិក្ខុនោះរម្ងាប់សះស្បើយទៅដោយ១រំពេច ព្រោះគិរិមានន្ទភិក្ខុបានស្តាប់នូវសញ្ញាទាំងឡាយ ១០ប្រការនេះ ។

អថខោ អាយស្មា អានន្ទោ ភគវតោ សន្តិកេ ឥមា ទស សញ្ញា ឧគ្គហេត្វា យេនាយស្មា គិរិមានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតោ គិរិមានន្ទស្ស ឥមា ទស សញ្ញា អភាសិ លំដាប់នោះ ព្រះអានន្ទត្ថេរដ៏មានអាយុក៏រៀននូវសញ្ញាទាំងឡាយ ១០ប្រការនេះ ក្នុងសំណាក់នៃព្រះដ៏មានព្រះភាគហើយចូលទៅត្រង់កន្លែងដែលគិរិមានន្ទលោកគង់នៅ លុះចូលទៅដល់ហើយទើបសំដែងនូវសញ្ញាទាំងឡាយ ១០ប្រការនេះ ដល់គិរិមានន្ទដ៏មានអាយុ ។

www.budinst.gov.kh www.elibraryofcambodia.org

អថខោ អាយស្មតោ គិរិមានន្ទស្ស ឥមា ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភិ លំដាប់នោះឯង អាពាធរបស់ព្រះគិរិមានន្ទ ដ៏មានអាយុនោះ ក៏រម្ងាប់សះស្បើយទៅដោយ ១រំពេច ព្រោះបានស្តាប់នូវសញ្ញាទាំងឡាយ ១០ប្រការនេះ ។

វុដ្ឋហិ ចាយស្មា គិរិមានន្ទោ តម្ហា អាពាធា ឯព្រះគិរិមានន្ទដ៏មានអាយុ ក៏បានជាសះស្បើយចាកអាពាធនោះ ។

តថា បហីនោ ច បនាយស្មតោ គិរិមានន្ទស្ស សោ អាពាធោ អហោសីតិ ក៏អាពាធនោះ គឺព្រះគិរិមានន្ទដ៏មានអាយុ លះបង់បានហើយ ដោយកិរិយាបានស្តាប់នូវសញ្ញាទាំង ១០ប្រការដែលព្រះអានន្ទត្រេរសំដែងដូច្នោះ ដោយប្រការដូច្នោះហោង ។

* ចប់គិរិមានន្ទ សូត្រ *

***********

******

ពិនិត្យអក្ខរាវិរុទ្ធ
ដោយ ខ្ញុំព្រះករុណាខ្ញុំបាទ ជិម ជំនិត

www.budinst.gov.kh www.elibraryofcambodia.org